# សេចក្តីសង្ខេប

របាយការណ៍អង្កេតនេះមានគោលបំណងស្វែងយល់អំពីតថភាពបច្ចុប្បន្ននៃធនធានទិន្នន័យបើកចំហនានាដែលមានស្រាប់ឬដែលកំពុងបង្កើតថ្មី ដែលពាក់ព័ន្ធនឹងដំណើរការគ្រប់គ្រងថវិការបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអំពីឱកាសនានាដើម្បីអភិវឌ្ឍវិស័យទិន្នន័យបើកចំហនៅកម្ពុជា។ ការអង្កេតនេះផ្តោតសំខាន់លើការកំណត់រកធនធានទិន្នន័យបើកចំហដែលមានប្រភពពីស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល និងសាកលវិទ្យាល័យនានា។ ការអង្កេតនេះក៏បានចងក្រងចេញជាបញ្ជីប្រភេទទិន្នន័យបើកចំហ និងវដ្តនៃការចេញផ្សាយទិន្នន័យនៅក្នុងប្រទេសកម្ពុជាផងដែរ។

ការអង្កេតនេះត្រូវបានធ្វើឡើងដោយផ្អែកលើការយល់ឃើញថាប្រព័ន្ធទិន្នន័យបើកចំហដែលមានដំណើរការល្អទាមទារឲ្យមានតុល្យភាពរវាងការផ្គត់ផ្គង់ (អ្នកផលិតទិន្នន័យ) និងតម្រូវការ (អ្នកប្រើប្រាស់ទិន្នន័យ) ដែលតុល្យភាពនេះអាចរក្សាបានដរាបណាហេដ្ឋារចនាសម្ព័ន្ធទិន្នន័យមានភាពរឹងមាំ។ ចំពោះផ្នែកតម្រូវការ ក្រុមអ្នកអង្កេតបានវាយតម្លៃលើភាពដែលអាចរកបាន និងភាពដែលអាចប្រើការបាននៃទិន្នន័យ របៀបគ្រប់គ្រងលើការប្រើប្រាស់ទិន្នន័យ និងការឲ្យតម្លៃទិន្នន័យបើកចំហពីសំណាក់អ្នកផលិតទិន្នន័យនានា។ ចំពោះផ្នែកផ្គត់ផ្គង់ យើងសិក្សាអំពីរបៀបដែលទិន្នន័យត្រូវបានប្រើប្រាស់ អំពីកង្វះខាតទិន្នន័យ និងអំពីរបៀបដែលអ្នកប្រើប្រាស់ឲ្យតម្លៃ និងចូលរួមចំណែកដល់ការអភិវឌ្ឍទិន្នន័យបើកចំហ។ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យវិញ ក្រុមការងារបានសិក្សាលម្អិតអំពីមុខងារ សមត្ថភាព និងភាពងាយស្រួលប្រើនៃផតថលវិប (web portal) ឬគេហទំព័រដែលផ្តល់លទ្ធភាពឲ្យអ្នកប្រើប្រាស់អាចទាញយកទិន្នន័យបាន។

តាមរយៈការសិក្សាឯកសារដែលមានស្រាប់ ក្រុមការងារបានវាយតម្លៃគេហទំព័រច្រើនជាង ១០០ ដែលត្រូវបានចាត់ទុកថាជាទីតាំងសក្តានុពលដែលអ្នកប្រើប្រាស់អាចទាញយកទិន្នន័យបើកចំហបាន។ ចំពោះការវាយតម្លៃលើការផ្គត់ផ្គង់និងតម្រូវការ យើងបានសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន ២៣ នាក់ ដែលរួមមានសាស្ត្រាចារ្យឬអ្នកស្រាវជ្រាវមកពីសាកលវិទ្យាល័យនានាចំនួន ៨ នាក់ បុគ្គលិកសង្គមស៊ីវិល ៤ នាក់ អ្នកសារព័ត៌មាន ៤ នាក់ អ្នកប្រឹក្សាយោបល់ឯករាជ្យ ៣ នាក់ និងមន្ត្រីរដ្ឋាភិបាល ៤ នាក់។ ការសម្ភាសទាំងនេះត្រូវបានបំពេញបន្ថែមដោយការស្ទង់មតិសាធារណៈមួយដោយប្រើប្រាស់កម្រងសំនួរឌីជីថល ហើយដែលទទួលបានការឆ្លើយតបចំនួន ៧៩ នាក់។ ជាសរុប មនុស្សចំនួន ១០២ នាក់ត្រូវបានស្ទង់មតិ ដែលក្នុងនោះមានស្រី ២៦ នាក់។

ឆ្លងតាមការវិភាគនៃទិន្នន័យដោយផ្អែកលើសំណាកគំរូដែលប្រមូលបាន វិសាលគមទិន្នន័យនៅក្នុងប្រទេសកម្ពុជាមានទិសដៅបាញ់ឆ្ពោះទៅរកការប្រើប្រាស់ ជាជាងការផលិត។ ការផលិតទិន្នន័យមានតែចំនួន ២០ ភាគរយនៃអ្នកឆ្លើយតបប៉ុណ្ណោះ។ ការចែកចាយទិន្នន័យពុំសូវទទួលបានការយកចិត្តទុកដាក់នោះទេ ដោយមានអ្នកឆ្លើយសំណួរតែ ១៣ ភាគរយប៉ុណ្ណោះដែលបាននិយាយថាស្ថាប័នរបស់ពួកគេបានចែកចាយទិន្នន័យដែលពួកគេបានផលិត។ លើសពីនេះទៀត នៅមានការយល់ដឹងទាបពីភាពខុសគ្នារវាងទិន្នន័យ និងព័ត៌មានក្នុងចំណោមអ្នកប្រើប្រាស់និងអ្នកផលិតទិន្នន័យ។

ការដាក់ឲ្យប្រើប្រាស់ទិន្នន័យបើកចំហនៅតាមស្ថាប័នសិក្សាស្រាវជ្រាវនានា ដូចជាសាកលវិទ្យាល័យជា

ដើម នៅពុំទាន់មានសកម្មភាពនៅឡើយទេ ទោះបីជាអ្នកស្រាវជ្រាវបានប្រមូលទិន្នន័យយ៉ាងច្រើនក៏ដោយ។ មានមូលហេតុចំបងចំនួនបួន ដូចជាកម្មសិទ្ធិបញ្ហា ការយល់ថាទិន្នន័យនឹងគ្មានអត្ថប្រយោជន៍អ្វីក្នុងការប្រើប្រាស់ក្រៅពីគម្រោងស្រាវជ្រាវផ្ទាល់ ការខ្លាចការរំលោភលើល័ក្ខខ័ណ្ឌដែលអ្នកឧបត្ថម្ភការស្រាវជ្រាវបានដាក់ឲ្យ និងអវត្តមានវេទិកាចែករំលែកទិន្នន័យដែលអាចទុកចិត្តបាន ដែលបានចូលរួមចំណែករារាំងពុំឲ្យមានការចែករំលែកទិន្នន័យដែលបានប្រមូលរួច។ ចំពោះអង្គការសង្គមស៊ីវិលវិញ ការផលិតទិន្នន័យតែងតែត្រូវបានបម្រុងទុកសម្រាប់ប្រើប្រាស់ក្នុងគម្រោងផ្ទាល់របស់ស្ថាប័ន ឬសម្រាប់ចែករំលែកដល់ក្រុមការងារតែប៉ុណ្ណោះ ហើយទិន្នន័យត្រូវបានគេចាត់ទុកថាគ្មានតម្លៃសាធារណៈ ឬផ្ទុកព័ត៌មានឯកជនច្រើនពេក។ ទោះយ៉ាងណាក៏ដោយ លទ្ធផលដែលបានពីទិន្នន័យទាំងនេះ ជារឿយៗត្រូវបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍គម្រោងរបស់ពួកគេ។ នៅថ្នាក់ជាតិ ក្នុងចំណោមគេហទំព័ររដ្ឋាភិបាលជាង ៥០ ដែលក្រុមអ្នកអង្កេតបានពិនិត្យសិក្សានោះ មួយភាគធំផ្តោតលើការផ្តល់ព័ត៌មាន ហើយមិនផ្តោតលើការផ្តល់ទិន្នន័យដល់សាធារណៈជនឡើយ។ នៅពេលដែលទិន្នន័យត្រូវបានផ្តល់ឲ្យអ្នកប្រើប្រាស់ ទិន្នន័យស្ទើរតែទាំងស្រុងត្រូវបានបង្ហាញជាទម្រង់សង្ខេបរួម ដូចជាតារាងតួលេខ ជារូបភាព ឬ អត្ថបទនៅក្នុងឯកសារ PDF ដែលពេលខ្លះគ្រាន់តែជាកំណែឌីជីថលដែលបានពីការស្កេនសំណៅដើមប៉ុណ្ណោះ។ តាមពិតនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ រដ្ឋាភិបាលកម្ពុជាពុំមានផតថលវ៉ិបសម្រាប់ចែករំលែកទិន្នន័យនោះទេ។ វាជាការណ៍ដែលគួរកត់ឲ្យសំគាល់ ដែលថាអង្គការសហប្រជាជាតិបានចែករំលែកទិន្នន័យអំពីប្រទេសកម្ពុជាដល់សាធារណៈជន ច្រើនជាងរដ្ឋាភិបាលកម្ពុជាខ្លួនឯង។

ទាក់ទងនឹងការប្រើប្រាស់ទិន្នន័យវិញ ស្ទើរតែ ៩០ ភាគរយនៃអ្នកឆ្លើយសំណួរបានបង្ហាញថាពួកគេបានប្រើប្រាស់ទិន្នន័យពីស្ថាប័នផ្សេង ដើម្បីបំពេញតម្រូវការទិន្នន័យរបស់ពួកគេ ដែលក្នុងនោះ ៨២ ភាគរយគឺដើម្បីគាំទ្រការស្រាវជ្រាវ ៧៤ ភាគរយសម្រាប់ការសរសេររបាយការណ៍ និង ៤៧ ភាគរយសម្រាប់ការអនុវត្តគម្រោង។ ទោះបីជាការវាយតម្លៃពេញលេញអំពីអក្ខរកម្មទិន្នន័យបើកចំហ និងអាកប្បកិរិយានៃការប្រើប្រាស់ទិន្នន័យមិនត្រូវបានធ្វើឡើងក៏ដោយ ក៏ភ័ស្តុតាងនានាមួយចំនួនបានបង្ហាញពីកម្រិតអក្ខរកម្មទិន្នន័យទាប និងឥរិយាបថលើការគ្រប់គ្រង និងការប្រើប្រាស់ទិន្នន័យបើកចំហដែលគួរឱ្យព្រួយបារម្ភ។ មានតែបីភាគរយប៉ុណ្ណោះនៃអ្នកចូលរួមក្នុងការអង្កេតនេះ ដែលបានយល់ដឹងត្រឹមត្រូវអំពីនិយមន័យនៃទិន្នន័យបើកចំហ។ ស្របគ្នានេះដែរ អ្នកសារព័ត៌មានទាំងអស់ដែលបានចូលរួមសម្ភាសបានឲ្យដឹងថាពួកគេមិនដឹងថាអ្វីដែលជាទិន្នន័យបើកចំហនោះទេ។ ពួកគេក៏បានអះអាងផងដែរថាសហសេវិករបស់ពួកគេនៅក្នុងវិស័យសារព័ត៌មានពុំត្រូវបានបណ្តុះបណ្តាលឱ្យធ្វើការជាមួយទិន្នន័យស្មុគស្មាញនោះទេ ហើយពួកគេខ្វះចំណេះដឹងលើការប្រើប្រាស់ទិន្នន័យ។ មួយភាគធំនៃអ្នកឆ្លើយសំណួរ (៤៥%) មិនដឹងថាអត្ថទិន្នន័យ (metadata) មានន័យដូចម្តេចនោះទេ។

កង្វះខាតខាងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យបើកចំហ និងអក្ខរកម្មទិន្នន័យបើកចំហទាប បានបង្កើតឲ្យមានការលំបាកយ៉ាងខ្លាំងសម្រាប់សហគមន៍ទិន្នន័យបើកចំហ។ ចន្លោះប្រហោងព័ត៌មាន ទិន្នន័យដែលមិនអាចជឿទុកចិត្តបានដែលបណ្តាលមកពីកង្វះខាតកំណត់ត្រាទិន្នន័យនិងអត្ថទិន្នន័យ និងគុណភាពទិន្នន័យទាប គឺជាបញ្ហាប្រឈមធំបំផុតបីដែលអ្នកប្រើប្រាស់ទិន្នន័យបានឲ្យដឹង។ ទោះយ៉ាងណា បញ្ហាប្រឈមនៃការអភិវឌ្ឍពិតប្រាកដកើតឡើងពីកត្តាទាំងក្នុងនិងក្រៅ។ នៅពេលដែលប្រទេសជាច្រើននៅក្នុងប្លុកអាស៊ានកំពុងបើកឃ្លាំងទិន្នន័យរបស់ខ្លួនឲ្យសា

ធារណៈជនរបស់គេប្រើប្រាស់ និងកំពុងវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ មានចម្ងល់ថាតើប្រជាជនកម្ពុជានឹងប្រឈមមុខជាមួយសេដ្ឋកិច្ចឌីជីថលដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សបែបណា ហើយអាចរក្សាបានសមត្ថភាពប្រកួតប្រជែងយ៉ាងដូចម្តេច? កង្វល់ជាច្រើនសម្រាប់រដ្ឋាភិបាលកម្ពុជាជុំវិញបញ្ហាប្រឈមនានាដែលបណ្តាលមកពីកង្វះសមត្ថភាពទិន្នន័យទាំងនេះ ជាប់ពាក់ព័ន្ធសំខាន់ទៅនឹងការរៀបចំខ្លួនរបស់រដ្ឋាភិបាលក្នុងការវិនិយោគលើការផលិតទិន្នន័យថ្មីៗ និងការកសាងប្រព័ន្ធចាកចាយទិន្នន័យ ដែលអាចធានាឲ្យមានលំហូរទិន្នន័យជាប់លាប់ទៅដល់ដៃអ្នកប្រើប្រាស់ ដែលនឹងឆ្នៃទិន្នន័យទាំងនោះឲ្យក្លាយទៅជាផលិតផលឬសេវាកម្មប្លែកៗដែលមានលក្ខណៈឆ្នៃប្រឌិតខ្ពស់។

បញ្ហាដែលបណ្តាលមកពីទិន្នន័យធំបំផុតដែលជះឥទ្ធិពលដល់គ្រប់វិស័យនៃការអភិវឌ្ឍគឺការមានទិន្នន័យបើកចំហតិចតួចបានកាត់បន្ថយសមត្ថភាពឃ្លាំមើលនិងតាមដានរបស់សាធារណៈជនទៅលើគំនិតផ្តួចផ្តើមអភិវឌ្ឍន៍នានារបស់រដ្ឋាភិបាល។ ការត្រួតពិនិត្យលើរដ្ឋាភិបាលតាមរយៈការប្រើប្រាស់ទិន្នន័យពិបាកនឹងសម្រេចបាន លើកលែងតែក្នុងករណីដូចជា គជអប ដែលបានផ្តល់ឲ្យសាធារណៈជនបានដឹងពីគំនិតផ្តួចផ្តើមអភិវឌ្ឍន៍នានារបស់រដ្ឋាភិបាលតាមរយៈមូលដ្ឋានទិន្នន័យសាធារណៈចំនួន ៩ របស់ពួកគេ។

ថ្វីបើមានបញ្ហាប្រឈមជាច្រើនក៏ដោយ វានៅមានឱកាសមួយចំនួនសម្រាប់ការលូតលាស់នៃទិន្នន័យបើកចំហ។ ឧទាហរណ៍មួយគឺគម្រោងពង្រឹងសមត្ថភាពស្ថាប័នឧត្តមសិក្សា (HEICP) ដែលគាំទ្រថវិកាដោយធនាគារពិភពលោក ដែលក្រោមគម្រោងនេះ ការស្រាវជ្រាវវិទ្យាសាស្ត្រជាច្រើននឹងត្រូវបានគាំទ្រ។ គម្រោងទាំងនេះនឹងត្រូវការទិន្នន័យបើកចំហច្រើនដោយជៀសមិនរួច ហើយទីបំផុតនឹងជំរុញឱ្យមានកំណើនការផលិតទិន្នន័យជាច្រើនផងដែរ។ ឧទាហរណ៍មួយទៀតគឺរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមទទួលស្គាល់ពីសារៈសំខាន់នៃផតថលទិន្នន័យបើកចំហដូចដែលបានបង្ហាញតាមរយៈការដាក់ឱ្យប្រើប្រាស់នូវផតថលទិន្នន័យរបស់ក្រសួងបរិស្ថាន។ ចំណាប់អារម្មណ៍មួយចំនួនលើប្រព័ន្ធព័ត៌មានភូមិសាស្ត្រស្ម័គ្រចិត្តក៏ត្រូវបានសង្កេតឃើញកើតមានផងដែរ។